# គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ១៩កម្ពុជា ទទួលបានសម្ភារតម្លៃប្រមាណ៣០ម៉ឺនដុល្លារ ពីវិស័យឯកជន និងសប្បុរសជនចំនួន១៤

2021-04-13 07:32pm

(ភ្នំពេញ)៖ រសៀលថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ នៅក្រសួងសុខាភិបាល ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា លោក លី ធុជ ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស បានសម្របសម្រួលជាមួយអ្នកវិនិយោគបរទេស និងសប្បុរសជនចំនួន១៤ តាមរយៈលោក Anthony Galliano ប្រធានសភាពាណិជ្ជកម្មអាមេរិកកាំងប្រចាំកម្ពុជា និងលោក Salah Essa នាំយកសម្ភារប្រគល់ជូនក្រសួងសុខាភិបាល តាមរយៈគណៈកម្មការចំពោះកិច្ច ចាក់វ៉ាក់សាំងកូវីដ-១៩ ដែលមានលោកស្រី ឱ វណ្ណឌីន ជាប្រធាន ដែលសម្ភារទាំងនោះ នឹងត្រូវយកមកប្រើប្រាស់សម្រាប់ការងារចាក់វ៉ាក់សាំងបង្ការកូវីដ-១៩ និងការងារប្រយុទ្ធប្រឆាំងនឹងការរីករាលជំងឺកូវីដ ផងដែរ។

សម្ភារដែលត្រូវប្រគល់ជូននោះ រួមមាន៖ រថយន្តដឹកវ៉ាក់សាំង០២គ្រឿង ដែលនឹងមកដល់កម្ពុជាក្នុងខែឧសភា ឆ្នាំ២០២១, កុំព្យូទ័រយួរដៃ, ម៉ាស៊ីន Printer, សម្លៀកបំពាក់ពេទ្យ(PPE), ម៉ាស់ និងសម្ភារផ្សេងៗដទៃទៀតសរុបថវិកាប្រមាណ ៣០ម៉ឺនដុល្លារអាមេរិក។

វិស័យឯកជន និងសប្បុរសជនទាំង១៤រួមមាន៖

*ទី១៖ Cambodia Rice Federation

*ទី២៖ RMA (Cambodia)

*ទី៣៖ SCG (Cambodia)

*ទី៤៖ SELA Pepper

*ទី៥៖ Marriott Courtyard Hotel

*ទី៦៖ Cambodian Investment Management

*ទី៧៖ DAGS Asset Management

*ទី៨៖ TANNCAM Investment

*ទី៩៖ Baker Tilly (Cambodia)

*ទី១០៖ Mr. Joseph Michael Couto

*ទី១១៖ លោក Salah Essa

*ទី១២៖ លោក Mark William Seymour

*ទី១៣៖ លោក Wells Matthew John Roland

*ទី១៤៖ កញ្ញា Narumon Rinruangsin។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា លោកទេសរដ្ឋមន្ត្រី បានកោតសរសើរ និងថ្លែងអំណរគុណចំពោះទុកចិត្តប្រកបដោយសប្បុរសចំពោះវិនិយោគិនបរទេស ដែលបានចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការងារទប់ស្កាត់ការរីករាលនៃជំងឺឆ្លងកូវីដ-១៩ ដែលបាននឹងកំពុងបង្ករជាហានិភ័យយ៉ាងខ្លាំងក្នុងប្រទេសកម្ពុជានាសព្វថ្ងៃនេះ។

លោកទេសរដ្ឋមន្ត្រី ក៏បានថ្លែងអំណរជូនចំពោះបណ្ដាក្រុមហ៊ុនវិនិយោគបរទេសទាំងអស់ ដែលបានដាក់ទុនវិយោគរកស៊ីនៅកម្ពុជា ព្រមទាំងបានបង្កើតនូវឱកាសការងារយ៉ាងច្រើនជូនចំពោះបងប្អូនប្រជាពលរដ្ឋ និងចូលរួមដល់កំណើនសេដ្ឋកិច្ចកម្ពុជាផងដែរ ក្រោមម្លប់សុខសន្តិភាព និងស្ថេរភាពនយោបាយ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជា។

ឆ្លៀតក្នុងឱកាសនោះ លោកទេសរដ្ឋមន្ត្រី បានសម្តែងនូវការដឹងគុណ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែង និងការពលីគ្រប់បែបរបស់ក្រុមគ្រូពេទ្យ ដែលបានបំពេញបេសកកម្មការងារដ៏មានតម្លៃ និងសកម្មបំផុត ក្នុងការជួយសង្គ្រោះអាយុជីវិតរបស់បងប្អូនប្រជាពលរដ្ឋកម្ពុជា ដែលទទួលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩។




គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ ១៩ (COVID-19)
ទីស្តីការក្រសួងសុខាភិបាល

FRESH NEWS PLUS
ព័ត៌មានកីឡា សិល្បៈ បច្ចេកវិទ្យា ចំណេះដឹង

bakertilly




គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ ១៩ (COVID-19)
ទីស្តីការក្រសួងសុខាភិបាល


គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ ១៩ (COVID-19)
ទីស្តីការក្រសួងសុខាភិបាល


គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ ១៩ (COVID-19)
ទីស្តីការក្រសួងសុខាភិបាល

FRESH NEWS PLUS
ព័ត៌មានកីឡា សិល្បៈ បច្ចេកវិទ្យា ចំណេះដឹង

bakertilly




គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ ១៩ (COVID-19)
ទីស្តីការក្រសួងសុខាភិបាល


គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ ១៩ (COVID-19)
ទីស្តីការក្រសួងសុខាភិបាល

FRESH NEWS PLUS
ព័ត៌មានកីឡា សិល្បៈ បច្ចេកវិទ្យា ចំណេះដឹង

bakertilly



FRESH NEWS PLUS
ព័ត៌មានកីឡា សិល្បៈ បច្ចេកវិទ្យា ចំណេះដឹង

bakertilly




គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ ១៩ (COVID-19)
ទីស្ដីការក្រសួងសុខាភិបាល
Ford


គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ ១៩ (COVID-19)
ទីស្ដីការក្រសួងសុខាភិបាល
SCG
K cement
Support Necessary Devices and Equipment for The Vaccination Centers
to the Ad-hoc Committee for Rolling Vaccination COVID-19
SCG


១៩ (COVID-19)
ទីស្តីការក្រសួងសុខាភិបាល

FRESH NEWS PLUS

bakertilly




Source: [https://www.freshnewsasia.com/index.php/en/localnews/193786-2021-04-13-12-32-09.html](https://www.freshnewsasia.com/index.php/en/localnews/193786-2021-04-13-12-32-09.html)